ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៧.១៣...០២.៣...០១១...ប្រកាសព័ត៌មាន

ថ្ងៃ អង្គារ ៣រោច ខែ ជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែមិថុនា ឆ្នាំ២០២៣

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់ការទូទាត់ឆ្លងដែនតាមរយៈឃ្យូអរកូដ (QR Code) រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ (ដំណាក់កាលទី ២៖ ថៃស្កេនឃ្យូអរកូដនៅកម្ពុជា)

នៅថ្ងៃអង្គារ ៣រោច ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា និង ឯកឧត្តម Sethaput Suthiwartnarueput ទេសាភិបាលធនាគារកណ្តាលថៃ បានអញ្ជើញជាអធិបតីក្នុងពិធីប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ការទូទាត់ឆ្លងដែនតាមរយៈឃ្យូអរកូដ (QR Code) រវាងព្រះរាជាណាចក្រកម្ពុជានិងព្រះរាជាណាចក្រថៃ (ដំណាក់កាលទី ២៖ ថៃស្កេនឃ្យូអរកូដនៅកម្ពុជា) នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ គម្រោងនៃការតភ្ជាប់ការទូទាត់ឆ្លងដែននេះ ចែកចេញជាពីរដំណាក់កាល ដែលដំណាក់កាលទី១ "កម្ពុជាស្កេនឃ្យូអរកូដនៅថៃ" និងដំណាក់កាលទី២ "ថៃស្កេនឃ្យូអរកូដនៅកម្ពុជា"។ ដំណាក់កាលទី១ ត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការក្នុងកិច្ចប្រជុំទ្វេភាគី រវាងធនាគារកណ្តាលនៃប្រទេសទាំងពីរ កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ ដែលបានអនុញ្ញាតឱ្យប្រជាជនកម្ពុជាដែលមានគណនីជាប្រាក់រៀល អាចប្រើប្រាស់កម្មវិធីធនាគារចល័តដើម្បីធ្វើការទូទាត់ប្រាក់តាមរយៈការស្កេនឃ្យូអរកូដ ទៅកាន់ពាណិជ្ជករ ឬនៅហាងទំនិញនៅប្រទេសថៃ ចំនួន ៧,៦ លានកន្លែង។ រីឯដំណាក់កាលទី២នៃគម្រោងនេះ ត្រូវបានដាក់ឱ្យប្រើប្រាស់ចាប់ពីថ្ងៃនេះតទៅ ដោយប្រជាជនថៃដែល មានគណនីជាប្រាក់បាតថៃ អាចទូទាត់ប្រាក់ដោយស្កេនឃ្យូអរកូដទៅកាន់ពាណិជ្ជករ ឬនៅហាងទំនិញប្រមាណ ១,៥ លានកន្លែង ក្នុងព្រះរាជាណាចក្រកម្ពុជា។

ពិធីនេះត្រូវបានធ្វើឡើង ក្រោមកិច្ចសហប្រតិបត្តិការដ៏រឹងមាំរវាងធនាគារកណ្តាលនៃប្រទេសទាំងពីរ បន្ទាប់ពីចុះអនុស្សរណៈយោគយល់ ស្តីពីកិច្ចសហប្រតិបត្តិការផ្នែកនវានុវត្តន៍ហិរញ្ញវត្ថុនិងប្រព័ន្ធទូទាត់សងប្រាក់ រវាងធនាគារជាតិនៃកម្ពុជានិងធនាគារកណ្តាលថៃកាលពីខែកុម្ភៈ ឆ្នាំ២០១៩



ប្រអប់សំបុត្រលេខ ២៥, ផ្ទះលេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ជាពិសេសការតភ្ជាប់ការទូទាត់ឆ្លងដែនរវាងប្រទេសទាំងពីរ ដែលប្រកបដោយសុវត្ថិភាព ងាយស្រួល និងតម្លៃសមរម្យ។ កិច្ចសហការនេះក៏ដើរទន្ទឹមនឹងគោលដៅរបស់សហគមន៍សេដ្ឋកិច្ចអាស៊ាន ក្នុងការលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិក្នុងទីផ្សារ និងបានរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញបរិយាបន្នហិរញ្ញវត្ថុ ព្រមទាំងពង្រឹងទំនាក់ទំនងសេដ្ឋកិច្ចកាន់តែជិតស្និទ្ធនិងទូលំទូលាយ រវាងព្រះរាជាណាចក្រកម្ពុជានិងព្រះរាជាណាចក្រថៃ ដែលនឹងគាំទ្រដល់ការស្តារសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិកូវីដ-១៩ និងអាចឈានដល់កិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុមួយកម្រិតទៀត ក្នុងការប្រើប្រាស់បច្ចេកវិទ្យា ដើម្បីជាប្រយោជន៍ដល់ប្រជាជននៃប្រទេសទាំងពីរ។

**ទំនាក់ទំនង ៖**
ផ្នែកទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣៩៩០១៩៦
អ៊ីម៉ែល ៖nbccommunication@nbc.gov.kh
**បណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា៖**
www.nbc.gov.kh, www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia , www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA